# ចាប់ពីកំណើតដល់អាយុ ប្រាំមួយឆ្នាំ – ការលូតលាស់ និងការវិវឌ្ឍ

*សូមសួរសំណួរ។ ទារកមិនអាចរង់ចាំបានទេ។*

Washington State Department of
CHILDREN, YOUTH & FAMILIES

## អ្វី

គំនូសតាងគឺត្រូវបានសរសេរឡើងសម្រាប់មាតាបិតា ប៉ុន្តែ អ្នកដែលដឹង ឬធ្វើការជាមួយក្មេងៗនឹងទទួលបានប្រយោជន៍ពីវាផងដែរ។

## ហេតុអ្វី

គំនូសតាងនៃការពិនិត្យជាមុននេះគឺជាវិធីសាស្ត្រឆាប់រហ័សមួយក្នុងការជួយអ្នកឲ្យកំណត់បាននូវចំណុចបញ្ហាដែលអាចកើតមានឡើងចំពោះការមើល ការស្តាប់ និងការវិវឌ្ឍរបស់កុមារ។ គំនូសតាងនឹងជួយអ្នកឲ្យពិនិត្យមើលកុមារទាំងស្រុងបាន។ អ្នកនឹងធ្វើការតាមដានទៅលើការវិវឌ្ឍរបស់កុមារទៅលើការគិត ជំនាញសង្គម ការស្តាប់ ការនិយាយ និងសកម្មភាពនៃការធ្វើចលនាផ្សេងៗ។ ជំនាញនៃការធ្វើចលនាខ្លះប្រើប្រាស់សាច់ដុំតូច (ដូចជាម្រាមដៃ) ផ្នែកផ្សេងទៀតប្រើប្រាស់សាច់ដុំធំ (ដូចជាជើង)។ វាជារឿងចាំបាច់ក្នុងការតាមដានលើការមើល និងការស្តាប់របស់កុមារនៅគ្រប់អាយុ។

**សំខាន់!** គំនូសតាងនេះជាវិធីសាស្ត្រឆាប់រហ័សក្នុងការជួយអ្នកឲ្យតាមដានពីការវិវឌ្ឍនៃការមើល ការស្តាប់ និងការវិវឌ្ឍរបស់កុមារ ហើយមិនមែនធ្វើឡើងក្នុងគោលបំណងជាតេស្ត ការវាយតម្លៃ ឬការវាស់ស្ទង់នៃការវិវឌ្ឍឡើយ។





## របៀបណា

ក្រុមអាយុនីមួយៗរាយសកម្មភាពដែលកុមារនឹងអាចធ្វើបាននៅពេលណាមួយនៅចន្លោះអាយុដំបូង និងអាយុទីពីរក្នុងក្រុមនោះ។ ឧទាហរណ៍ គិតត្រឹមរយៈពេល 12 ខែ កុមារៗនឹងអាចធ្វើសកម្មភាពដែលបានរាយនៅក្នុងក្រុមអាយុពី 6 ដល់ 12 ខែ។ យ៉ាងណាមិញ កុមារភាគច្រើននឹងមិនអាចធ្វើសកម្មភាពទាំងអស់នេះនៅអាយុ 6 ខែបានទេ។ វាដូចគ្នាចំពោះក្រុមអាយុនីមួយៗ។ ដូចនេះ សូមកុំមានក្តីបារម្ភពេក ប្រសិនបើកុមារនៅពេលផ្តើមនៃកម្រិតអាយុនីមួយៗនេះ មិនអាចធ្វើសកម្មភាពទាំងអស់នេះបាន។ ដោយហេតុថាកុមារមានការវិវឌ្ឍនៅអត្រាមួយខុសៗគ្នា សូមកុំមានការភ័យព្រួយដោយសារតែក្មេងហាក់ដូចជាមានភាពយឺតយ៉ាវក្នុងកិច្ចការណាមួយ។

អានសកម្មភាពដែលបានរាយនៅក្រោមអាយុរបស់ក្មេង និងក្រោមផ្នែកនៃការមើល និងការស្តាប់។ មើល និងស្តាប់នៅពេលដែលកុមារលេង។ តើក្មេងអាចធ្វើសកម្មភាពទាំងនេះទេ? វាចាំបាច់ដែលកុមារមានពេលវេលា ទីកន្លែង និងសម្ភារដែលត្រូវការសម្រាប់សកម្មភាពនីមួយៗ។ ឧទាហរណ៍ សូមកុំនិយាយថាកុមារមិនអាចគូរមុខបាន ប្រសិនបើអ្នកមិនបានឲ្យក្រដាស និងប៊ិច ឬខ្មៅដៃទៅកុមារ។

អ្នកអាចមើល និងស្តាប់កុមាររយៈពេលបីបួនថ្ងៃជាប់គ្នា ដោយប្រើគំនូសតាងកត់ត្រាពីក្តីបារម្ភណាដែលអ្នកមាន។ ប្រសិនបើកុមារនៅកម្រិតនៃក្រុមអាយុខ្ពស់មិនអាចធ្វើសកម្មភាពទាំងអស់បាន ក្រុមគ្រួសារអាចចែករំលែកការអង្កេតរបស់ពួកគេជាមួយអ្នកមានជំនាញវិជ្ជាជីវៈដែលអាចពិនិត្យលម្អិតពីការអភិវឌ្ឍរបស់កុមារបាន។

## នៅពេលណា

មើល និងស្តាប់នៅពេលដែលកុមារកំពុងលេង។ អ្នកកំពុងស្វែងរកមើលថាតើកុមារជាធម្មតាចូលចិត្តអ្វី។ **សូមកុំប្រើគំនូសតាងនេះនៅពេលដែលក្មេងឈឺ អស់កម្លាំង ឬទទួលការរំខាន។**

## អ្វីបន្ទាប់មកទៀត

អ្នកអាចទូរស័ព្ទទៅលេខរបស់ Help Me Grow Washington ដែលបានបង្ហាញនៅផ្នែកម្ខាងទៀតនៃឯកសារចុះផ្សាយនេះ សម្រាប់ឈ្មោះនៃ Lead Family Resources Coordinator (FRC) ក្នុងមូលដ្ឋាននៅក្នុងតំបន់របស់អ្នក ប្រសិនបើអ្នកមានក្តីបារម្ភអំពីការវិវឌ្ឍរបស់កុមារ។ ពេទ្យកុមារ ក្រសួងសុខាភិបាល ឬមណ្ឌលសិក្សាធិការសាលារៀន ក៏អាចជួយដល់ក្រុមគ្រួសារ ព្រមទាំងរូបអ្នកក្នុងការស្វែងរកភ្នាក់ងារដែលនៅជិតដែលអាចធ្វើការពិនិត្យពេញលេញបន្ថែមទៀតទៅលើការវិវឌ្ឍ ការមើល និង/ឬការស្តាប់របស់កុមារ។



## ការមើល

*តើកូនរបស់អ្នក...*

- ☐ សម្លឹងកែវភ្នែក (មើលភ្នែករបស់អ្នក)
- ☐ មើលតាមរបស់ដែលផ្លាស់ទីដោយប្រើភ្នែករបស់ពួកគេ
- ☐ ដើរ ឬវារដោយមិនបុកទៅនឹងវត្ថុផ្សេងៗញឹកញាប់
- ☐ មើលទៅមនុស្ស និងវត្ថុផ្សេងៗដោយប្រើភ្នែកទាំងពីរ
- ☐ កាន់វត្ថុនៅចម្ងាយធម្មតា (បន្ទាប់ពីអាយុ 6 ខែ)
- ☐ ដើរ ឬវាបានរលូនកាត់ស្រមោល ឬតំបន់ដែលមានសភាពខុសគ្នា (ព្រំ ឥដ្ឋ)
- ☐ មើលមនុស្ស ឬវត្ថុផ្សេងៗដោយមិនស្រលៀងភ្នែក ឬប្រឹងសម្លឹង (បន្ទាប់ពី 9 ខែ)
- ☐ មានភ្នែកដែលថ្លាច្បាស់ មិនក្រហម ឬមានចេញទឹក

## ការស្តាប់

*តើកូនរបស់អ្នក...*

- ☐ បង្ហាញពីភាពដឹងនៃសំឡេងក្នុងផ្ទះ (សំឡេងទូរស័ព្ទ សំឡេងគោះទ្វារ សំឡេងទូរទស្សន៍)
- ☐ ប្រើសំឡេងដែលមិនខ្លាំងពេក ឬតិចពេក
- ☐ លេងជាមួយល្បែងដែលមានសំឡេង (កណ្តឹងអង្រួន កណ្តឹង)
- ☐ ត្រាប់តាមសំឡេង (បន្ទាប់ពី 1 ឆ្នាំ)
- ☐ ប្រើប្រាស់ពាក្យខាងចុងខ្លះៗ (“s” ឬ “ing”) បន្ទាប់ពីអាយុពីរឆ្នាំ
- ☐ ធ្វើតាមការណែនាំពាក្យសម្តី
- ☐ រក្សាសំឡេងមធ្យមលើទូរទស្សន៍ ឬវិទ្យុ
- ☐ ស្តាប់រឿង ខ្សែអាត់សំឡេង ឬទូរទស្សន៍ដោយគ្មានបញ្ហា
- ☐ និយាយ ដូចនេះមនុស្សភាគច្រើនអាចយល់បាន (ប្រសិនបើអាយុលើស 2-1/2 ឆ្នាំ)
- ☐ ដើរមករកអ្នកនៅពេលហៅចេញពីបន្ទប់មួយផ្សេងទៀត (បន្ទាប់ពី 2 ឆ្នាំ)

# ចាប់ពីកំណើតដល់អាយុប្រាំមួយឆ្នាំ–ការលូតលាស់ និងការវិវឌ្ឍ

## *សូមសួរសំណួរ។ ទារកមិនអាចរង់ចាំបានទេ។*

Washington State Department of
CHILDREN, YOUTH & FAMILIES



## សម្រាប់មាតាបិតា៖

ក្នុងនាមជាមាតាបិតា អ្នកជាមនុស្សដែលសំខាន់ជាងគេក្នុងជីវិតរបស់កូនរបស់អ្នក។ អ្នកស្គាល់ពីកូនរបស់អ្នកបានច្បាស់ជាងគេ។ ប្រសិនបើអ្នកមានក្តីបារម្ភអំពីការវិវឌ្ឍរបស់កូនអ្នក អ្នកអាចស្នើសុំការវាយតម្លៃបាន។ សូមសួរសំណួរប្រសិនបើអ្នកមានសំណួរ ឬក្តីបារម្ភណាមួយ។ ទូរស័ព្ទទៅ Help Me Grow Washington ដើម្បីទទួលបានឈ្មោះនៃ Family Resources Coordinator (FRC) ប្រចាំតំបន់ដែលអាចជួយអ្នកបាន។

## សម្រាប់អ្នកផ្តល់សេវា៖

កុមារលូតលាស់ និងវិវឌ្ឍតាមរបៀបខុសគ្នា។ សូមព្យាយាមជជែកជាមួយក្រុមគ្រួសារអំពីការវិវឌ្ឍកូនរបស់ពួកគេជាទៀងទាត់។ សួរពួកគាត់ពីជំនាញថ្មីៗដែលកូនរបស់ពួកគាត់បានរៀន ហើយក្តីបារម្ភអ្វីដែលពួកគេមាន ព្រមទាំងចែករំលែកពីការអង្កេតរបស់អ្នកផងដែរ។ ត្រូវជម្រាបក្រុមគ្រួសារឲ្យបានដឹងផងដែរថា ប្រសិនបើពួកគាត់មានក្តីបារម្ភ ព័ត៌មាន និងជំនួយបន្ថែមអាចស្វែងរកបានតាមរយៈការទូរស័ព្ទទៅលេខរបស់ Help Me Grow Washington ។ ពួកគេនឹងបញ្ជូនគ្រួសារបន្តទៅកាន់ Family Resources Coordinator (FRC) ប្រចាំតំបន់នៅក្នុងតំបន់របស់ពួកគាត់។ អ្នកក៏អាចទូរស័ព្ទទៅ Help Me Grow Washington ដើម្បីសុំឈ្មោះ និងលេខទូរស័ព្ទរបស់ FRC ហើយចែករំលែកព័ត៌មាននេះជាមួយក្រុមគ្រួសារដោយផ្ទាល់ផងដែរ។

### ចាប់ពីពេលកើត-3ខែ *តើកូនរបស់អ្នក...*

- ☐ លើកក្បាល ឬទ្រូងរបស់ពួកគេនៅពេលដាក់ផ្កាប់លើពោះ
- ☐ ធ្វើចលនាដៃ និងជើងរបស់ពួកគេបានយ៉ាងងាយស្រួល
- ☐ មើលតាមចលនារបស់អ្នកដោយបែរក្បាលរបស់ពួកគេពីម្ខាងទៅម្ខាង
- ☐ ងាយស្រួលចាប់យកដបទឹក ឬសុដន់ហើយជញ្ជក់បានល្អ
- ☐ ភ្ញាក់ ឬយំនៅពេលមានសំឡេងខ្លាំងមួយរំពេច
- ☐ មើលមកអ្នក មើលមុខរបស់អ្នក
- ☐ បញ្ចេញសំណើច ឬសំឡេងស្រទន់
- ☐ ញញឹមឆ្លើយតបនឹងការញញឹម ឬការជជែករបស់អ្នក
- ☐ ស្ងប់ស្ងាត់យ៉ាងងាយនៅពេលដែលលួងលោម

### 3-6ខែ *តើកូនរបស់អ្នក...*

- ☐ លេងជាមួយជើងនៅពេលដាក់ដេកផ្ងារ
- ☐ លើកក្បាល ឬទ្រូងរបស់ពួកគេដោយទម្ងន់សង្កត់លើដៃនៅពេលដាក់ផ្កាប់លើពោះ
- ☐ ទប់ក្បាលបញ្ឈរ នឹងទប់ជំហរដោយមិនត្រូវការជំនួយ
- ☐ ក្រឡាប់ខ្លួនពីពោះមកខ្នង និងពីខ្នងមកពោះ
- ☐ លេងជាមួយដៃខ្លួនឯងដោយការប៉ះគ្នាទៅវិញទៅមក
- ☐ ឈោងចាប់របស់លេង
- ☐ ចាប់យករបស់លេងដែលដាក់នៅកន្លែងអាចយកដល់
- ☐ បែរក្បាលទៅរកសំឡេង
- ☐ ធ្វើសំឡេងច្រើនខុសៗគ្នា
- ☐ សើចលឺខ្លាំង
- ☐ ព្យាយាមបង្ហាញការពេញចិត្ត និងមិនពេញចិត្ត

### 6-12ខែ *តើកូនរបស់អ្នក...*

- ☐ លើកខ្លួនឯងឈរដោយត្រូវការជំនួយខ្លះ
- ☐ អង្គុយដោយមិនត្រូវការជំនួយនៅពេលកំពុងលេងរបស់លេង
- ☐ ផ្ទេរវត្ថុពីដៃមួយទៅដៃមួយទៀត
- ☐ចេះញ៉ាំដោយដៃដោយខ្លួនឯង
- ☐ គ្រាប់តាមការក្រវីដៃ លាហើយ
- ☐ ចេះប្រាប់អ្នកឲ្យដឹងពីតម្រូវការរបស់ពួកគេដោយធ្វើកាយវិការ និងសំឡេង
- ☐ គ្រាប់តាមសំឡេងសម្តី ("ba-ba", "ga-ga")
- ☐ ចេះដូរវេននៅពេលលេងជាមនុស្សពេញវ័យ (សកម្មភាព សំឡេង ការបង្ហាញអារម្មណ៍តាមរយៈផ្ទៃមុខ)
- ☐ ចេះប្រាប់ឲ្យអ្នកបានដឹងថាពួកគេយល់ពីសំណួរសាមញ្ញ ("តើត្រូវការទៀតឬទេ?")
- ☐ ស្គាល់ឪពុកម្តាយ និងមនុស្សចម្លែក

### 12-18ខែ *តើកូនរបស់អ្នក...*

- ☐ ដើរតែម្នាក់ឯង
- ☐ ចាប់កាន់វត្ថុតូចៗ (ទំហំប៉ុនគ្រាប់ទំពាំងបាយជូរ)
- ☐ ដាក់វត្ថុទៅក្នុង និងបោះចោលចេញពីប្រអប់
- ☐ ដាក់វត្ថុបន្ទុបពីលើវត្ថុមួយផ្សេងទៀត
- ☐ ចេះញ៉ាំដោយខ្លួនឯងដោយប្រើស្លាបព្រា
- ☐ អាចនិយាយបានពាក្យ ពីរ ឬបីម៉ាត់ខុសៗគ្នាបន្ថែមទៀតក្រៅពីពាក្យ "Mama" ឬ "Dada"
- ☐ សុំរបស់ផ្សេងៗដោយប្រើប្រាស់ពាក្យ
- ☐ កាន់ និងផឹកដោយប្រើកែវដោយមានកំពប់ខ្លះ
- ☐ ចង្អុលទៅវត្ថុ ឬរូបភាពមួយចំនួននៅពេលហៅឈ្មោះ

### 18ខែ-2ឆ្នាំ *តើកូនរបស់អ្នក...*

- ☐ ដើរឡើង និងចុះជណ្តើរដោយប្រើដៃទប់
- ☐ គូរវាស
- ☐ ធ្វើកាយវិការដងខ្លួនទៅតាមតន្រ្តី
- ☐ បញ្ចូលពាក្យពីរជាមួយគ្នា ("ថែមទឹកផ្លែឈើ")
- ☐ ចាប់ផ្តើមសួរសំណួរ, ("ទឹកផ្លែឈើ?", "បាយ បាយ?")
- ☐ ញ៉ាំសាំងវិចដោយខ្លួនឯង ចេះខាំ
- ☐ ដោះស្រោមជើង និងស្បែកជើង
- ☐ មើលរូបភាពក្នុងសៀវភៅរឿងជាមួយមនុស្សពេញវ័យ
- ☐ ចេះធ្វើការជ្រើសរើសសាមញ្ញលើរបស់របរលេង (ល្បែងល្បងប្រាជ្ញា ឬឡាន)
- ☐ គ្រាប់តាមការលេងរបស់ក្មេងដ៏ទៃទៀត (ការចាក់ខ្សាច់ គប់បាល់)

### 2-3ឆ្នាំ *តើកូនរបស់អ្នក...*

- ☐ ដើរ រត់ ឈប់ ដើរឡើង នឹងអង្គុយចោងហោងបានល្អ
- ☐ បន្តុបរបស់3 ឬច្រើនជាងនេះលើគ្នា
- ☐ ប្រើស្លាបព្រា និងកែវដោយខ្លួនឯង
- ☐ ធ្វើតាមការណែនាំពីរជំហាន ("យកសៀវភៅហើយដាក់វាលើតុ")
- ☐ ឲ្យឈ្មោះផ្នែកលើរាងកាយរបស់ពួកគេបានពីប្រាំទៅប្រាំមួយ
- ☐ ចូលរួមក្នុងកិច្ចសន្ទនាសាមញ្ញ
- ☐ ឆ្លើយសំនួរសាមញ្ញ "អ្វី" និង "តើអ្វី" ("តើចង់ញ៉ាំអ្វីសម្រាប់អាហារថ្ងៃត្រង់?")
- ☐ ចង្អុល ឬឲ្យឈ្មោះវត្ថុពេលដែលប្រាប់ពីការប្រើរបស់វា ("តើយើងផឹកដោយប្រើអ្វី?")
- ☐ ជួយក្នុងកិច្ចការសាមញ្ញៗ (រើសយករបស់លេង)
- ☐ ប្រើប្រាស់ប្រយោគមាន 2-3 ពាក្យជាញឹកញាប់

### 3-4ឆ្នាំ *តើកូនរបស់អ្នក...*

- ☐ លោត រត់ គប់ ឡើង ដោយមានលំនឹងល្អ
- ☐ គូររង្វង់ បន្ទាត់ សញ្ញាខ្វែងដោយប្រើគូល័រផាត់ពណ៌
- ☐ ប្រើរបស់លេង និងវត្ថុផ្សេងទៀតដើម្បីធ្វើពុធជាលេង
- ☐ ចូលចិត្តសៀវភៅមានរូបភាព ហើយចូលចិត្តឲ្យគេអានឲ្យស្តាប់
- ☐ យល់ពីពាក្យដែលប្រាប់ពីទីកន្លែងវត្ថុរក្សាទុក (ខាងក្រោយ ក្រោម ក្នុង លើ)
- ☐ ប្រើការនិយាយដែលងាយស្រួលយល់
- ☐ សួរសំណួរ "ហេតុអ្វី" និង "អ្វី" ច្រើន
- ☐ ចូលចិត្តលេងជាមួយកុមារដទៃទៀត
- ☐ ចេះចាំវេនខ្លួនឯងនៅពេលខ្លះ
- ☐ ឆ្លើយតបសំនួរងាយៗ "កន្លែងណា" និង "នរណា"

### 4-5ឆ្នាំ *តើកូនរបស់អ្នក...*

- ☐ លោត រាំ ឬលេងល្បែងផ្សេងទៀតដែលប្រើប្រាស់សាច់ដុំធំ (ដូចជាជើង)
- ☐ លោតឈរលើជើងមួយ
- ☐ គូរមុខដែលមើលទៅដូចមុខ
- ☐ ពាក់សម្លៀកបំពាក់ដោយត្រូវការជំនួយខ្លះ
- ☐ សួរសំណួរដោយប្រើពាក្យ "អ្វី កន្លែងណា នរណា និង ហេតុអ្វី"
- ☐ និយាយសំឡេងពាក្យភាគច្រើនបានយ៉ាងច្បាស់លើកលែងតែសំឡេង "s, z, th, និង r"
- ☐ ប្រើប្រាស់ពាក្យដែលបង្ហាញពីទំហំ និងតួលេខ (ធំ ច្រើន)
- ☐ និយាយទាំងពីរ ទាំងឈ្មោះខ្លួន និងនាមត្រកូល
- ☐ ចូលចិត្តលេងជាមួយកុមារដែលមានអាយុដូចគ្នា

### 5-6ឆ្នាំ *តើកូនរបស់អ្នក...*

- ☐ ចូលចិត្តចាប់ គប់ ទាត់បាល់
- ☐ មានលំនឹងល្អនៅពេលលេងល្បែងប្រើសាច់ដុំធំ (ល្បែងដេញគ្នា ល្បែងលោត លេងវាយកូនបាល់)
- ☐ ចូលចិត្តកាត់របស់ដោយប្រើកន្ត្រៃ
- ☐ ស្លៀកពាក់ខ្លួនឯង ដោយមានកិបឡេវ បិត និងរូត
- ☐ បង្ហាញចំណាប់អារម្មណ៍ក្នុងការសរសេរពាក្យជជែកដូចជាការជជែកលេងជាមួយគ្រួសារ (ប្រើប្រាស់ប្រភេទពាក្យ និងប្រយោគដូចគ្នា)
- ☐ អនុវត្តតាមការណែនាំបីជំហានតាមការបញ្ជាប្រាប់ ("យកបាល់ ដាក់ក្នុងប្រអប់របស់លេង ហើយដើរមកកាន់តុ។")
- ☐ និយាយឈ្មោះពេញ អាយុ និងភេទរបស់ខ្លួន
- ☐ ចូលចិត្តលេងល្បែងដែលមានក្បួនខ្នាតជាមួយក្មេងដ៏ទៃទៀត (Simon និយាយ រត់ដេញគ្នា)

### ទាក់ទង៖


**The Washington State Department of Children, Youth & Families Early Support for Infants និង Toddlers Program**

PO Box 40970
Olympia, Washington
98504-0970

**esit@dcyf.wa.gov**

**www.dcyf.wa.gov/services/child-development-supports/esit**

**Help Me Grow Washington ទូរស័ព្ទ៖**
1-800-322-2588



*DCYF មិនរើសអើង និងផ្តល់លទ្ធភាពទទួលបានកម្មវិធី និងសេវាកម្មរបស់ខ្លួនស្មើគ្នាដល់មនុស្សទាំងអស់ដោយមិនគិតពីជនជាតិ ពណ៌សម្បុរ យេនឌ័រ សាសនា ជំនឿ ស្ថានភាពអាពាហ៍ពិពាហ៍ ដើមកំណើតជាតិសាសន៍ ទំនោរផ្លូវភេទ អាយុ ស្ថានភាពអតីតយុទ្ធជន ឬមានពិការភាពផ្លូវកាយ ពិការភាពវិញ្ញាណ ឬពិការភាពផ្លូវចិត្តឡើយ។*

*ប្រសិនបើអ្នកចង់បានច្បាប់ចម្លងដោយឥតគិតថ្លៃនៃការចេញផ្សាយនេះជាទម្រង់ ឬភាសាផ្សេងទៀត DCYF Constituent Relations (ទំនាក់ទំនងសំខាន់របស់DCYF) តាមលេខ 1-800-723-4831 ឬផ្ញើអ៊ីមែលទៅ communications@dcyf.wa.gov ។*



DCYF PUBLICATION FS_0030 | DEL 11-002 CA (07-2023) Cambodian